**ប្រការ ៣ :** ឯកឧត្តម អស់លោកដូចមានរាយនាមក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា និងត្រា
**គាត ឈន់**

* * *

# ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាស

**ប្រកាសលេខ ២១៧ គរ.ប្រក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧**

**ប្រការ ១ :** អនុញ្ញាតអោយក្រុមហ៊ុនហ្គោលដិន ដូហ្វិន ត្រេឌីង លីមីធិតមានអាស័យដ្ឋានផ្ទះលេខ ១៨ B មហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ធ្វើអាជីវកម្មនិងប្រើប្រាស់ថ្មកំបោរដើម្បីផលិត ស៊ីម៉ងត៍នៅតំបន់ភ្នំទូកមាសខាងកើតដែលរួមមានភ្នំតុហាហ្លួង និង ភ្នំកូនសត្វ ស្រុកបន្ទាយមាស ខេត្តកំពត លើផ្ទៃដីសរុបចំនួន ៦៣៧.៧៥ ហិតា ហើយដែលមានកូអរដូណេដូចតទៅ ÷

| ចំណុច | អាប់ស៊ីស | អ័រដោណេ |
|---|---|---|
| B : | $4\;48^{50}$ | $11\;79^{50}$ |
| C : | $4\;51^{00}$ | $11\;79^{50}$ |
| D : | $4\;51^{00}$ | $11\;77^{00}$ |
| H : | $4\;49^{75}$ | $11\;77^{00}$ |
| I : | $4\;49^{75}$ | $11\;77^{25}$ |
| j : | $4\;48^{50}$ | $11\;77^{25}$ |

**ប្រការ ២ :** ក្រុមហ៊ុនហ្គោលដិន ដូហ្វិន ត្រេឌីង លីមីធិត ត្រូវដំណើរការធ្វើអាជីវកម្ម និង ប្រើប្រាស់ថ្មកំបោរដើម្បីផលិតស៊ីម៉ង់ត៍តាមបរិមាណដែលបានកំណត់ក្នុងគំរោងវិនិយោគរបស់ខ្លួននិង ដោយធានាអនុវត្តតាមលក្ខណៈបច្ចេកទេសអាជីវកម្ម ។

**ប្រការ ៣ :** ប្រកាសនេះមានតំលៃដល់ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៧ ។ ក្នុងកំឡុងពេល ៩០ ថ្ងៃមុនផុតកំណត់ពេលនៃប្រកាសនេះ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណធ្វើអាជីវកម្ម និងប្រើប្រាស់ ថ្មកំបោរ ដើម្បីផលិតស៊ីម៉ង់ត៍បន្ត ។

**ប្រការ ៤ :** ប្រកាសនេះនឹងត្រូវដកហូតវិញ ក្នុងករណីក្រុមហ៊ុនប្រព្រឹត្តិល្មើសទៅលើលក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងធ្វើអាជីវកម្មនិងប្រើប្រាស់ថ្មកំបោរ ឬ កិច្ចព្រមព្រៀងនោះត្រូវបញ្ចប់តាមប្រការ ២៥ នៃកិច្ចព្រមព្រៀង ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
**ពូ សុធីរៈ**

* * *

**ប្រកាសលេខ ២១៨ ឧក.ប្រក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧**

**ប្រការ ១ :** អនុញ្ញាតអោយរោងជាងផលិតគ្រឿងសង្ហារឹម«ហេង ងៀប»ដែលមានលោក សារ៉ាម ចន្ទណារិទ្ធិ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៩៩០១៨ ភ.ព ចុះថ្ងៃទី ១៥–៧–៩២ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ២៤៧ សង្កាត់ទឹកល្អក់ទី ៣ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ បើកដំណើរការ ផលិតកម្មនៅក្នុងទីតាំង ភូមិ ក្បាល អូររាំង ឃុំ សែនមនោរម្យ ស្រុក អូររាំង ខេត្ត មណ្ឌលគិរី ។

**ប្រការ ២ :** ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់រោងជាត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិស្ថាន ធានាគុណភាពផលិតផលព្រមទាំងត្រូវគោរពរាល់ច្បាប់និងបទបញ្ញត្តិដែលមានជាធរមាន ។

**ប្រការ ៣ :** រោងជាងនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្តៈ គ្រោងគុ ទូ កៅអី បង្គោលខ្សែភ្លើង បង្គោលស្ពាន និង ក្ដារទ្រុងឡាន ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតផល គឺ ឈើកៅស៊ូ ផ្ដៅ និង ដើមឬស្សីដែលមានលក្ខណៈស្របច្បាប់ ដែលសាមីរោងជាងត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

**ប្រការ ៤ :** ម្ចាស់រោងជាងត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាពផលិតកម្មរបស់រោងជាងផ្ញើជូនមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្ត មណ្ឌលគិរី ។